**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខៈ ២៨៥
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
សំណុំរឿងជំនុំជម្រះលេខៈ ១៩០
ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០
សាលក្រមលេខៈ ៥៦ "ជ"
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ ២
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ២:៣០នាទីល្ងាច
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៩:០០នាទីព្រឹក

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ២៨៥ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] HELLOCO VALERY ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិបារាំង សាសនាគ្រិស្ត កើតនៅទីក្រុងLoudeac មានទីលំនៅបច្ចុប្បន្ននៅRUA DO SACRAMENTO A LAPA NO 14 1200-794 LISBOA PORTUGAL កម្រិតវប្បធម៌ អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម មុខរបរ ប្រធានអគ្គនាយក្រុមហ៊ុន Vikoria Invest (អតីតEEM) ឪពុកឈ្មោះ [redacted] HELLOCO GUY "រ" ម្តាយឈ្មោះ [redacted] DANIELE "ស" ប្រពន្ធឈ្មោះ [redacted] EMILIE មានកូនចំនួន ០២នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន (គេចខ្លួន)។

២-ឈ្មោះ [redacted] ALBERT PRONK ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិហូឡង់ សាសនាគ្រិស្ត កើតនៅទីក្រុងRIO DE JANEIRO ប្រទេសប្រេស៊ីល មានទីលំនៅបច្ចុប្បន្ននៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ បរិញ្ញាបត្រគ្រប់គ្រងសណ្ឋាគារ និងបដិសណ្ឋារកិច្ច មុខរបរ គ្មាន ឪពុកឈ្មោះ [redacted] LEO PRONK "រ" ម្តាយឈ្មោះ [redacted] SILVIA PASSARINI "រ" នៅរស់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន (គេចខ្លួន)។

ជនជាប់ចោទទាំងពីរនាក់មានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិ។

**ត្រូវជាប់ចោទពីបទៈ រំលោភលើលំនៅឋាន និងប្រឆាំងនឹងមន្ត្រីរាជការសាធារណៈ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ និងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩៩ និងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] Gontier ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិបារាំង មានទីលំនៅបច្ចុប្បន្ន នៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១២៤៦/១៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៧៧៣៩ "ឌ"/២០១៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ២៦១ ពស.ព្រជ (ក) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោម តាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ដំណើររឿងហេតុកើតឡើងមានដូចតទៅ</u>

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] HELLOCO VALERY ដែលមិនមានឈ្មោះ និងតួនាទីក្នុងក្រុមហ៊ុន (VAK) និងឈ្មោះ [redacted] ALBERT PROMK ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងាររួចហើយនៅបានរំលោភលើទីតាំងសណ្ឋាគារ និងកំហែងយកត្រួតត្រាគ្រប់គ្រងសណ្ឋាគារទាំងបំពានដែលក្រុមហ៊ុននេះឈ្មោះ [redacted] GONTIER សញ្ជាតិបារាំង កំពុងគ្រប់គ្រងតាមអំណាចសាលដីកាលេខៈ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល។ លើសពីនេះឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PROMK បានធ្វើសកម្មភាពរាំងដល់កម្លាំងសមត្ថកិច្ចចុះបំពេញការងារផ្ទាល់ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ធ្វើឲ្យមានការប៉ះពាល់ដល់សតិអារម្មណ៍បុគ្គលិក និងនយោជិក និងធ្វើឲ្យខូចខាតផលប្រយោជន៍ក្រុមហ៊ុន ព្រមទាំងផលប្រយោជន៍ច្បាប់យ៉ាងធ្ងន់ធ្ងរ។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ូផា បានឆ្លើយថាៈ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] HELLOCO VALERY ដែលមិនមានឈ្មោះ និងតួនាទីក្នុងក្រុមហ៊ុន (VAK) និងឈ្មោះ [redacted] ALBERT PRONK ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងាររួចហើយនៅបានរំលោភលើទីតាំងសណ្ឋាគារ និងកំហែងយកត្រួតត្រាគ្រប់គ្រងសណ្ឋាគារទាំងបំពានដែលក្រុមហ៊ុននេះឈ្មោះ [redacted] GONTIER សញ្ជាតិបារាំង កំពុងគ្រប់គ្រងតាមអំណាចសាលដីកាលេខៈ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល។ លើសពីនេះឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK បានធ្វើសកម្មភាពរាំងដល់កម្លាំងសមត្ថកិច្ចចុះបំពេញការងារផ្ទាល់ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ធ្វើឲ្យមានការប៉ះពាល់ដល់សតិអារម្មណ៍បុគ្គលិក និងនយោជិក និងធ្វើឲ្យខូចខាតផលប្រយោជន៍ក្រុមហ៊ុន ព្រមទាំងផលប្រយោជន៍ច្បាប់យ៉ាងធ្ងន់ធ្ងរ។



Scanned with CamScanner

-តាមរំណាកនចម្លើយរបស់សាក្សីឈ្មោះ [redacted] រ៉ា បានឆ្លើយថា៖ ខ្លួនជាអ្នកសម្របសម្រួលសន្តិសុខសណ្ឋាគារ Victoria ស្ថិតនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ ពីមុនឈ្មោះ PATRICK មានតួនាទីជាអនុប្រធានចាត់ការទូទៅក្នុងសណ្ឋាគារ ហើយត្រូវបានសណ្ឋាគារបញ្ឈប់ពីមុខតំណែងកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨។ បានរយៈពេលប្រហែលមួយសប្តាហ៍ក្រោយមកឈ្មោះ PATRICK បានចូលមកបំរើការងារក្នុងសណ្ឋាគារវិញដោយទទួលការងារដដែល ដោយផ្នែកខាងរដ្ឋបាលពុំបានទទួលលិខិតអនុញ្ញាតឲ្យចូលបំរើការងារវិញនោះទេ។ ក្រោយមកបានប្រហែល ២-៣ថ្ងៃឃើញខាងសមត្ថកិច្ចចូលមកជួបគាត់ បន្ទាប់មកឈ្មោះ [redacted] HELLOCO VALERY បានប្រាប់ឲ្យឈ្មោះ PATRICK ឈប់ធ្វើការងារ និងចាកចេញពីសណ្ឋាគារចាប់ពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ហើយនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ខ្លួនឃើញឈ្មោះ [redacted] HELLOCO VALERY បានចាកចេញពីសណ្ឋាគារដែរ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមលឿន បានឆ្លើយថា៖ ខ្លួនជាអ្នកបម្រើការងារនៅសណ្ឋាគារ Victoria មានតួនាទីជាអ្នកគ្រប់គ្រងធនធានមនុស្ស។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៦:០០នាទីខ្លួនកំពុងធ្វើការស្រាប់តែឈ្មោះ រ៉េត រ៉ា បានមកប្រាប់ខ្លួនថាឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK បានប្រាប់ខ្លួនថាចូលបម្រើការងារវិញហើយ។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១០ព្រឹកក៏មានសមត្ថកិច្ចចុះមកដល់សណ្ឋាគារ ហើយជួបជាមួយឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK ហើយបានឲ្យអ្នកទាំងពីរចេញពីសណ្ឋាគារ។

-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានការពារថា ជនជាប់ចោទឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK បានប្រើឧបាយកលរំលោភត្រួតត្រាគ្រប់គ្រងសណ្ឋាគារ Victoria Angkor Resort & Spa ទាំងបំពាន ហើយជនជាប់ចោទទាំងពីរនាក់នេះក៏បានរារាំង ដល់កម្លាំងសមត្ថកិច្ចចុះបំពេញការងារផ្ទាល់ដើម្បីអនុវត្តច្បាប់ទោះបីមិនបានប្រព្រឹត្តអំពើហិង្សាក៏ដោយ ប៉ុន្តែវាក៏បានបង្ហាញពីការបង្កប់ដោយអំពើរារាំងប្រឆាំងតទល់ពេញទំហឹង គឺជាបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងអ្នករាជការសាធារណៈ។ ក្នុងនាមកូនក្តីខ្លួន ខ្លួនមានសំណូមពរសូមឲ្យតុលាការសម្រេចផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK តាមច្បាប់ និងសងសំណងការខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុន និងជម្ងឺចិត្តព្រមទាំងសោហ៊ុយផ្លូវច្បាប់ផ្សេងៗស្មើនឹងទឹកប្រាក់ចំនួន ១០០,០០០,០០០៛ (មួយរយលានរៀល)។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថាពិតជាមានអង្គហេតុដូចការចោទប្រកាន់ប្រាកដមែន ហេតុដូច្នេះតំណាងអយ្យការសូមរក្សាបទចោទ ប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ២៨៥ អយ្យ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល និងប្តឹង[illegible] តុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សិទ្ធិនិយាយស្តីរបស់ជនជាប់ចោទបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

ផ្អែកតាមកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ និងប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមរបាយការណ៍សំយោគលេខៈ ០២៦/១៨ កសអ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ឲ្យដឹងថាៈ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ និងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ជនជាប់ចោទឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK ពិតជាបានចូលទៅគ្រប់គ្រងសណ្ឋាគារ VICTORIA ANGKOR RESORT & SPA ស្ថិតនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយគ្មានការអនុញ្ញាតពីឈ្មោះ [redacted] GONTIER ដែលជាប្រធានក្រុមប្រឹក្សាភិបាលសណ្ឋាគារ ប្រាកដមែន។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] HELLOCO VALERY ដែលមិនមានឈ្មោះ និងតួនាទីក្នុងក្រុមហ៊ុន (VAK) និងឈ្មោះ [redacted] ALBERT PRONK ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងាររួចហើយនៅបានរំលោភលើទីតាំងសណ្ឋាគារ និងកំហែងយកត្រូតត្រាគ្រប់គ្រងសណ្ឋាគារទាំងបំពានដែលក្រុមហ៊ុននេះឈ្មោះ [redacted] GONTIER សញ្ជាតិបារាំង កំពុងគ្រប់គ្រងតាមអំណាចសាលដីកាលេខៈ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល។ បន្ទាប់មកនៅពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK បានធ្វើសកម្មភាពរារាំងដល់កម្លាំងសមត្ថកិច្ចចុះបំពេញការងារផ្ទាល់ធ្វើឲ្យមានការប៉ះពាល់ដល់សតិអារម្មណ៍បុគ្គលិក និងនយោជិក ដែលធ្វើឲ្យខូចខាតផលប្រយោជន៍ក្រុមហ៊ុន ព្រមទាំងផលប្រយោជន៍ច្បាប់យ៉ាងធ្ងន់ធ្ងរ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សីមានលក្ខណៈស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK ពិតជាបានធ្វើសកម្មភាពរំលោភលើលំនៅឋាន និងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ឈ្មោះខាងលើទាំងពីរនាក់នេះបានធ្វើសកម្មភាពប្រឆាំងនឹងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ប្រាកដមែន។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងពីរនាក់នេះ គឺជាបទល្មើសលួច ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩៨ និងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១២៤៦/១៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិនិត្យ និងសម្រេចតាមការស្នើសុំ។

-អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តច្បាប់របស់អាជ្ញាធរសាធារណៈ ប៉ះពាល់ដល់ទីកន្លែងរបស់បុគ្គលឯកជន សន្តិសុខសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋជាធរមាន។

-មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមានបញ្ហាស្មារតី គឺបញ្ជាក់បានថាជនជាប់ចោទមានសតិល្អត្រឹមត្រូវ និងយល់ដឹងបានពីអំពើដែលខ្លួនបានប្រព្រឹត្ត គឺជាបទល្មើសព្រហ្មទណ្ឌ តែជននេះនៅតែប្រព្រឹត្ត។

-មានភស្តុតាងដាក់បន្ទុក ធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] HELLOCO VALERY ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិបារាំង និងឈ្មោះ [redacted] ALBERT PRONK ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិហូឡង់ ពីបទ: **រំលោភលើលំនៅឋាន និងប្រឆាំងនឹងមន្ត្រីរាជការសាធារណៈ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ និងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩៩ និងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណានចម្លើយតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១០០,០០០,០០០រ (មួយរយលានរៀល) គប្បីតុលាការសម្រេចតាមព្យសនកម្មជាក់ស្តែងដែលកើតឡើងចំពោះជនរងគ្រោះ។

## សាលាដំបូង ខេត្តសៀមរាប
## វិនិច្ឆ័យសេចក្តី

I-ផ្តន្ទាទោសជនជាប់ចោទ

ក/-ឈ្មោះ [redacted] HELLOCO VALERY ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិបារាំង (អត្តសញ្ញាណដូចខាងលើ)

ខ/-ឈ្មោះ [redacted] ALBERT PRONK ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិហូឡង់ (អត្តសញ្ញាណដូចខាងលើ)

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល **០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ០១ (មួយ) លានរៀល ចូលថវិការដ្ឋ។**

ពីបទ: **រំលោភលើលំនៅឋាន និងប្រឆាំងនឹងមន្ត្រីរាជការសាធារណៈ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ និងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩៩ និងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

II-បង្គាប់ឲ្យឈ្មោះ [redacted] HELLOCO VALERY និងឈ្មោះ [redacted] ALBERT PRONK រួមគ្នាសងសំណងជម្ងឺចិត្តចំនួន **១០ (ដប់) លានរៀល** ឲ្យទៅឈ្មោះ [redacted] Gontier ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**
ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០
**ចៅក្រមជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប, ថ្ងៃទី...៣០...ខែមេ៣ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]